**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០៤ សរ...

# សារាចរ

## ស្តីពី

## យន្តការត្រួតពិនិត្យ តាមដាន ថ្លៃសម្ភារៈកសិកម្ម

កំណើនសេដ្ឋកិច្ចកម្ពុជាដែលធ្លាប់បានកើនឡើង គួរជាទីមោទនៈ ក្នុងរយៈពេល ០៤ឆ្នាំ ចុងក្រោយនេះ កំពុងរងផលប៉ះពាល់ពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងនិនភាពសេដ្ឋកិច្ចសាកលលោក។ ប៉ុន្តែទោះជាស្ថិតក្នុងស្ថានភាពបែបនេះក៏ដោយ ក៏វិស័យសេដ្ឋកិច្ចកម្ពុជានៅតែអាចជំនះ និង រក្សាបាននូវសក្តានុពលខ្ពស់ ដែលអាចបន្តកំណើនក្នុងកម្រិតសមស្រប ដោយសារការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២**" ជាពិសេស តាមរយៈការដាក់វិធានការឆ្លើយតបក្នុងវិស័យផលិតកម្មស្រូវ អង្ករ ដែលជាកត្តាគន្លឹះដ៏សំខាន់ ដើម្បីជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។

ស្ថិតក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានបន្តអនុវត្តគោលនយោបាយថវិកាទន់ភ្លន់មួយ ដោយមានវិធានការអនុគ្រោះខាងសារពើពន្ធ គឺកំណត់អត្រាពន្ធគយសូន្យភាគរយ និង ដាក់អាករតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ លើការនាំចូលសម្ភារៈកសិកម្មជាអាទិ៍ ពូជ ជី ថ្នាំកសិកម្ម ចំណីសត្វ និង សម្ភារៈឧបករណ៍កសិកម្មផ្សេងទៀត ក្នុងគោលបំណងជួយដល់កសិករក្នុងការកាត់បន្ថយតម្លៃដើមផលិត ដើម្បីបង្កើនការប្រកួតប្រជែងលើទីផ្សារ ជាពិសេសក្នុងការនាំចេញផលិតផលស្រូវ អង្ករ។

ដើម្បីលើកកំពស់ការអនុវត្តគោលនយោបាយនេះ ចាំបាច់ត្រូវមានយន្តការសម្របសម្រួលអន្តរក្រសួងមួយ ដែលទទួលខុសត្រូវនាំមុខដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការតាមដាន ត្រួតពិនិត្យថ្លៃសម្ភារៈកសិកម្មសំខាន់ៗខាងលើបម្រើឱ្យផលិតកម្មកសិកម្ម រាជរដ្ឋាភិបាលសម្រេចដាក់វិធានការដូចខាងក្រោម ៖

១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចត្រួតពិនិត្យ តាមដានព័ត៌មានស្តីពីថ្លៃទីផ្សារក្នុងស្រុកនៃសម្ភារៈកសិកម្ម ជាពិសេស ជី ដែលលក់ចែកចាយក្នុងប្រទេសសម្រាប់បម្រើឱ្យផលិតកម្មកសិកម្ម។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវសហការឱ្យបានល្អក្នុងការបញ្ជូនព័ត៌មាន និង ជម្រុញការផ្សព្វផ្សាយព័ត៌មានថ្លៃទីផ្សារសម្ភារៈកសិកម្មឱ្យដល់កសិករនៅមូលដ្ឋាន។

៣-ក្រសួងពាណិជ្ជកម្មមានភារកិច្ច តាមដាន ព័ត៌មានអំពីថ្លៃទីផ្សារក្រៅប្រទេស និងប្រទេសប្រភពដើមផលិត នាំចេញ នូវបណ្តាសម្ភារៈកសិកម្មខាងលើ ដែលបម្រើឱ្យផលិតកម្មកសិកម្មក្នុងប្រទេស។

៤-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា) មានភារកិច្ចធ្វើសម្រង់ព័ត៌មានស្តីពីថ្លៃនាំចូល និង បរិមាណសម្ភារៈកសិកម្ម ដែលនាំចូលជាក់ស្តែង តាមមាត់ច្រកគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា។

៥-ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) ត្រូវផ្តល់ព័ត៌មានស្តីពីថ្លៃសម្ភារៈកសិកម្ម តាមភារកិច្ចរបស់ខ្លួនជាប្រចាំរៀងរាល់ដំណាច់ខែ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមគំរូតារាងកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការបូកសរុប ប្រមូលផ្តុំទិន្នន័យ និង ចេញព្រឹត្តបត្រព័ត៌មានប្រចាំខែស្តីពីថ្លៃទីផ្សារសម្ភារៈកសិកម្ម។

៦-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការវាយតម្លៃលើការប្រែប្រួលថ្លៃទីផ្សារសម្ភារៈកសិកម្ម ក្នុងករណីចាំបាច់ដែលអាចប៉ះពាល់ដល់ផលិតកម្មកសិកម្មក្នុងប្រទេស ដើម្បីរាយការណ៍ស្នើសុំវិធានការពីរាជរដ្ឋាភិបាល។

ទទួលបានសារាចរនេះ ក្រសួងស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៩

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ពន្ធ័
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ